# ៧- រឿងឧកញ៉ាយោមរាជ និង ឧកញ៉ាពលទេព

កាលពីព្រេងនាយ មាននាម៉ឺនពីរនាក់ ម្នាក់ជាទីឧកញ៉ាយោមរាជ ម្នាក់ទៀតជាឧកញ៉ាពលទេព ។ ឯឧកញ៉ាពលទេពជាមនុស្សលោភបុណ្យស័ក្តិ ចង់បានទីយោមរាជ កើតគំនិតស្អប់ឧកញ៉ាយោមរាជគិតស្វែងរកទោសដាក់នឹងក្រាបទូលស្តេចទម្លាក់ចាកទីយោមរាជ អាត្មាឯងនឹងបានស្តីទីយោមរាជនោះតទៅ ។ ឧកញ៉ាពលទេពស្វែងរកទោសលោកយោមរាជនោះជាយូរខែមក ថ្ងៃមួយមានអ្នកទោសម្នាក់ជាប់ទោសធ្ងន់ ក្រុមជំនុំកាត់ទោសដល់ប្រហារជីវិត ។ ឯអ្នកទោសនោះដឹងថាថ្ងៃព្រឹកស្អែកនេះ គេនឹងនាំអាត្មាទៅសម្លាប់ជាប្រាកដ ក៏តាំងសៅសោកវិយោគស្តាយជីវិតមហិមា យំពណ៌នាថា " ឱ ! ជីវិតអញអើយ ! ព្រឹកស្អែកនេះហើយនឹងបង់ចាកប្រាណ អើត្រង់ក្តីស្លាប់ ១ នេះនរណាឡើយនឹងវៀរបង់បាន តែកើតឡើងហើយ រមែងតែងស្លាប់ជាធម្មតា តែថាត្រង់ជីវិត ១ នេះទោះបង់បាត់ទៅក្តី ក៏មិនសូវជាសោកស្តាយអ្វីប៉ុន្មាន មកសោកស្តាយតែវិជ្ជា ១ ដែលខ្លួនបានចេះហើយពុំទាន់បានបង្ហាត់បង្ហាញនរណា១សោះ បើព្រឹកនេះខ្លួនស្លាប់ហើយ វិជ្ជានេះយល់នឹងជាសូន្យសោះ អស់មាននរណាមួយក្នុងលោកនេះ អាចចេះតទៅទៀតបានឡើយ " ។

កាលនោះមាននាយឆ្មាំពន្ធនាគារម្នាក់ បានឮចៅនោះពណ៌នាសោកស្តាយវិជ្ជាដូច្នោះ ក៏ចូលទៅសាកសួរថា " ចៅឯងព្រឹកនេះ ដល់ទីស្លាប់ប្រាកដហើយ ចៅយំរៀបរាប់ថាត្រង់ជីវិត រូបកាយមិនសូវជាស្តាយប៉ុន្មាន មកស្តាយវិជ្ជា ១ដែលចេះមក តើវិជ្ជានោះឈ្មោះវិជ្ជាអ្វី ចៅចេះវិជ្ជាអ្វី ចូរប្រាប់យើងមើល " ។

ឯអ្នកទោសក៏ប្រាប់ថា " ខ្ញុំបាទចេះវិជ្ជាស្តាប់ភាសាសត្វ វិជ្ជានេះវិសេសរបស់ខ្ញុំបាទណាស់ ក្នុងលោកនេះគ្មាននរណាចេះសោះ តែខ្ញុំបាទដល់ទីស្លាប់ហើយ វិជ្ជានេះសូន្យតែម្តងព្រោះពុំមាននរណាបានមករៀនតទៅឡើយ " ។ នាយឆ្មាំពន្ធនាគារឮដូច្នោះ ក៏នាំសេចក្តីនោះទៅជម្រាបលោកឧកញ៉ាយោមរាជសព្វប្រការ ។ ឧកញ៉ាយោមរាជក៏នឹកក្នុងចិត្តថា វិជ្ជានេះវិសេសក្រៃពេក គួរតែរៀនយក ទើបនាំនាយឆ្មាំពន្ធនាគារ

ទៅដោះអ្នកទោសចាកទីឃុំឃាំង ហើយសួរបញ្ជាក់ថា ពិតឬ ពុំពិត ។ អ្នកទោសក៏ជម្រាបថា " នេះ ពិតប្រាកដមែន " ឧកញ៉ាយោមរាជថា " បើយើងសុំរៀនពីចៅឯង តើបានឬមិនបាន ? ហើយវិជ្ជានេះតម្លៃប៉ុន្មាន ? " ។

អ្នកទោសថា " ខ្ញុំបាទជូនព្រះតេជព្រះគុណបាន សូមព្រះតេជព្រះគុណរៀនតទៅចុះតែអត់អំពីខ្ញុំប្របាទនេះហើយវិជ្ជានេះនឹងសូន្យជាប្រាកដតែការនឹងរៀននោះតោងទៅតាំងពិធីរៀន នៅក្នុងព្រះវិហារចំពោះព្រះភក្ត្រព្រះបដិមាករជាប្រធានឯគ្រឿងកំណាល់គ្រូនោះមិនមានអ្វីច្រើនទេ ត្រូវការតែទៀន ៥ ធូប ៥ លាជ ៥ ផ្កា ៥ ប៉ុណ្ណោះឯង អញ្ជើញព្រះតេជព្រះគុណរៀបរៀនឱ្យឆាប់ចុះ តែព្រឹកស្អែកខ្ញុំប្របាទលាព្រះតេជព្រះគុណទៅស្រុកខ្មោចហើយ " ។

ឧកញ៉ាយោមរាជធ្វើតាម ទើបឱ្យនាយឆ្មាំពន្ធនាគារនាំខ្លួនអ្នកទោសទៅវត្ត ក៏នាំចូលទៅក្នុងព្រះវិហារ ឱ្យបិទទ្វារវិហារជិតទាំងអស់ពុំឱ្យមនុស្សណាមួយឮឡើយ ឧកញ៉ាយោមរាជក៏តាំងរៀបទៀនធូបលាជផ្កា នៅចំពោះព្រះភក្ត្រព្រះ ហើយថា " ពិធីរៀននោះតើដូចម្ដេចខ្លះចូរចៅបង្គាប់ទៅមើល យើងនឹងធ្វើតាម " អ្នកទោសបង្គាប់ឱ្យអុជទៀនធូបហើយឱ្យលោកយោមរាជនិងខ្លួនវាក្រាបថ្វាយបង្គំព្រះ សូត្រនមស្ការពុទ្ធគុណធម្មគុណ សង្ឃគុណ ចាប់ចុះហើយអ្នកទោសប្រណម្យដៃពោលដង្ហោយឡើងថា "ឱ ! ព្រះដ៏មានបុណ្យព្រះគុណប្រកបដោយមហាករុណាតែងប្រោសមេត្តាសត្វដែលកើតមានក្ដី វិបត្តិចូលមកពឹងពោធិសម្ភារជួយ ដោះទុក្ខសត្វឱ្យសត្វបានក្ដីសុខសម្រាន្តទាំងលោកនេះនិងបរលោក ព្រះពុទ្ធជាម្ចាស់អើយ ! ខ្ញុំព្រះករុណានេះ ត្រូវទោសធំណាស់ព្រឹកស្អែកនេះហើយលោកឧកញ៉ាយោមរាជនឹងឱ្យនាំទៅប្រហារជីវិតខ្ញុំព្រះករុណាៗ មានក្ដីភិតភ័យខ្លាចក្ដីស្លាប់នោះជាបំផុត ស្ដាយជីវិតក្រៃពេកព្រះគុណអើយ ! សូមព្រះអង្គទ្រង់ប្រោសបិណ្ឌបាតជីវិតខ្ញុំព្រះករុណា អំពីលោកឧកញ៉ាយោមរាជនេះឱ្យលោកប្រោសលែងខ្ញុំ ឱ្យរួចចាកក្ដីស្លាប់ក្នុងគ្រាម្ដងនេះ " ថាហើយអ្នកទោសវាទៅក្រាបទៀបបាទជើងលោកយោមរាជហើយដង្ហោយថា " ឱព្រះតេជព្រះគុណអើយ ! សូមប្រោសអត់ទោសខ្ញុំប្របាទនេះ ហេតុដែលខ្ញុំប្របាទសោកពោលថា " ស្ដាយវិជ្ជាចេះភាសាសត្វនោះខ្ញុំមិនចេះវិជ្ជានោះទេ គឺខ្ញុំសោកស្ដាយជីវិតពិតៗគិតបញ្ឆោតឱ្យព្រះតេជព្រះគុណអញ្ជើញមកកាន់ព្រះវិហារនេះឯង ដើម្បីឱ្យព្រះសម្មាសម្ពុទ្ធជាម្ចាស់ គឺព្រះពុទ្ធរូបនេះទ្រង់បិណ្ឌបាតជីវិតខ្ញុំប្របាទអំពីព្រះតេជព្រះគុណ ឱព្រះតេជព្រះគុណអើយ ! ប្រោសថ្វាយជីវិតខ្ញុំប្របាទដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទៅឥឡូវព្រះអង្គទ្រង់បិណ្ឌបាតហើយព្រះគុណអើយ ! ការបូជាដោយគ្រឿងអាមិសទានឯទៀតៗ នោះមានផលានិសង្សពុំស្មើនឹងការបូជាជីវិតខ្ញុំប្របាទ ដល់ព្រះពុទ្ធជាម្ចាស់ក្នុងគ្រានេះឡើយ ផលនេះហើយជាផលយ៉ាងធំបំផុត ព្រះតេជព្រះគុណនិងប្រាថ្នាសាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាចសម្រេចដូចក្ដីប្រាថ្នាទៅអនាគតកាល " ។ ឯលោកឧកញ៉ាយោមរាជ លុះឮពាក្យអ្នកទោសពោលដង្ហោយដូច្នោះ ក៏ដូចជាគេខ្មាស់ណែនឱរ៉ា នឹកឃើញថា ចាញ់កលឧបាយអ្នកទោសជាប្រាកដ ទើបនិយាយទៅកាន់នាយឆ្មាំពន្ធនាគារថា " អើយើងចាញ់កលអ្នកទោសនេះហើយ ឥឡូវវាពោលពាក្យដង្ហោយសូមជីវិតវានឹងព្រះពុទ្ធរូប វាអង្វរព្រះពុទ្ធថា ឱ្យទ្រង់បិណ្ឌបាតទោសវាឯងជាម្ដង ការនេះតែយើងមិនលែងវា ក៏ដូចជាយើងមិនយល់ដល់ព្រះពុទ្ធជាម្ចាស់ ហាក់ដូចជាយើងឥតសទ្ធា ក្នុងព្រះពុទ្ធសាសនាបើដូច្នេះនាយឆ្មាំឯងនឹងខ្ញុំ យើងពីរនាក់ចូលសទ្ធាលើកជីវិតវា ថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចុះ ហើយយើងពីរនាក់ទទួលកែខៃជាក្រោយគឺយើងបិទបាំងឱ្យជិតកុំឱ្យខ្ចរខ្ចាយឮដល់ត្រចៀកអ្នកដទៃឯទៀតឡើយ " ។

ឯនាយឆ្មាំក៏ព្រមតាម ទើបលោកយោមរាជឱ្យនាយឆ្មាំស្រាយចំណងហើយថា "យើងលែងចៅឯងហើយ ចូរចៅរត់ទៅនៅទីណាមួយ ដែលជាទីរក្សាជីវិតឯងចុះ ហើយកុំនិយាយប្រាប់គេថា យើងដោះលែងចៅឯង ចៅឯងចូរថាកាច់ច្រវាក់រត់ចាកគុកទៅចុះតទៅមុខទៀតចៅកុំប្រព្រឹត្តការលាមកយ៉ាងនេះទៀតឡើយ " ។ ឯអ្នកទោសក៏ក្រាបថ្វាយបង្គំព្រះហើយក្រាបលាលោកយោមរាជ និងនាយឆ្មាំហើយក៏រត់ចេញទៅស្រុកក្រៅ លាក់ខ្លួនពុំឱ្យពួករាជការដឹងឮឡើយ ។

ឯឧកញ៉ាយោមរាជ  ក៏នាំនាយឆ្មាំថ្វាយបង្គំលាព្រះពុទ្ធរូបហើយវិលទៅកាន់លំនៅៗជាសុខសប្បាយ កំចាយតែសព្ទប្រាប់គេថា អ្នកទោសនោះកាច់ច្រវាក់រត់ចេញចាកគុកទៅបាត់ហើយ ។ លុះកន្លងកាលយូរមក រឿងនោះពុំស្ងាត់បាត់ទៅឡើយ ជាហេតុឱ្យដឹងឮទៅដល់ឧកញ៉ាពលទេព១ មានចិត្តត្រេកអរដោយសមតាមគំនិត ដែលគិតរកឱកាសនឹងក្រាបទូលព្រះរាជាឱ្យដកងារឧកញ៉ាយោមរាជនេះ អាត្មាគង់នឹងបានទីនោះ ។ សម័យថ្ងៃមួយជាពេលាព្រឹក ព្រះរាជាស្តេចចេញអង្គាសភត្ត ដាក់បាត្រលោកសង្ឃស្តេចកំពុងទុកបាត្រ មានហ្វូងក្អែកទាំងឡាយហើរមកស្រែកកញ្ជ្រៀវកងរំពងទាំងផ្ទៃវាំង ក្អែកពួកខ្លះហើរស្រែកយំ ទំតាមដើមឈើតាមដំបូលប្រាសាទ ដំបូលដំណាក់ទីទៃៗ ។

ឯព្រះបរមចក្រី លុះស្តេចទុកបាត្រស្រេចហើយ ទ្រង់ត្រាស់ថាអាសត្វក្អែកអស់នេះ មានហេតុភេទអ្វី បានជាថ្ងៃនេះវានាំគ្នាមកស្រែកគឹកកងកោលាហលយ៉ាងនេះធ្វើម្តេចនឹងបានដឹងភាសាវាអេះ ! " ។

ឯឧកញ៉ាពលទេពអង្គុយគាល់នៅទីនោះ លុះបានឮព្រះបន្ទូលដូច្នោះបានឱកាសទើបក្រាបទូលឡើងថា " សូមទ្រង់ព្រះមេត្តាប្រោសមនុស្សយើងទាំងឡាយ ក្នុងព្រះនគរនេះពុំមាននរណាមួយអាចចេះភាសាសត្វឡើយ ឮថាអ្នកឧកញ៉ាយោមរាជ គេចេះភាសាសត្វ ដោយគេបានរៀនតអំពីអ្នកទោសដល់ទីប្រហារជីវិតម្នាក់ ហើយបានលែងអ្នកទោសជាគ្រូគេនោះបង់ សូមទ្រង់ព្រះមេត្តាប្រោសឱ្យហៅមកសួរគង់ទ្រង់ជ្រាប " ។ ព្រះរាជាបានទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏ប្រើរាជបម្រើម្នាក់ ឱ្យទៅហៅឧញ៉ាយោមរាជចូលមកគាល់ ។ ឧកញ៉ាយោមរាជឮថាទ្រង់មានព្រះរាជឱង្ការឱ្យហៅទៅគាល់ដូច្នោះ ក៏នឹកពិភាល់ក្នុងចិត្តថា ទ្រង់ឱ្យរកខ្លួនចូលទៅនេះ មុខជាមានការប្លែកប្រាកដ ទើបសួរទៅកាន់រាជបម្រើនោះថា " នាហ្មឺនណាគាល់នៅក្នុងទីនោះខ្លះ ? " ។ រាជបម្រើជម្រាបថា " លោកឧកញ៉ាពលទេពគាល់នៅទីនោះ " ។ ឧកញ៉ាយោមរាជឮដូច្នោះ ក៏ដឹងខ្លួនថាអាពលទេពវាគង់ក្រាបទូល ពោលទោសអញជាប្រាកដ គិតហើយឧកញ៉ាយោមរាជរៀបអាត្មាម៉ីម្មាទៅជាមួយនឹងរាជបម្រើនោះ លុះដល់ហើយក៏ចូលទៅក្រាបបង្គំអង្គុយគាល់ក្នុងទីដ៏គួរសម ។ ឯព្រះរាជាទតយល់ឧកញ៉ាយោមរាជចូលមកគាល់ហើយ ក៏ត្រាស់ថា " អើអ្នកយោមរាជ ឥឡូវឧកញ៉ាពលទេពគេប្រាប់យើងថា អ្នកឯងបានរៀនភាសាសត្វអំពីអ្នកទោសម្នាក់ ហើយអ្នកឯងបានលែងអ្នកទោសនោះ ចេញចាកគុកទៅ ឥឡូវហ្វូងសត្វក្អែកទាំងឡាយវាមកស្រែកកញ្ជ្រៀវកងរំពងជាកោលាហលយល់ជានឹងមានហេតុអ្វីមួយពុំខាន បើដូច្នេះអ្នកឯងចេះភាសាសត្វ ចូរស្តាប់វានិយាយគ្នាទៅមើល " ។ ឧកញ៉ាយោមរាជក៏ទទួលព្រះឱង្ការទូលអនុលោមតាមថា " ខ្លួនបានរៀនចេះដឹងភាសាសត្វពិតប្រាកដមែន " លុះឮព្រះឱង្ការប្រើឱ្យស្តាប់សត្វក្អែកដូច្នោះ ក៏ធ្វើជាបែរផ្ទៀងត្រចៀកស្តាប់សព្ទក្អែកម្ខាង ហើយបែរទៅស្តាប់សព្ទក្អែកម្ខាងទៀត លុះស្ងប់សព្ទក្អែកបន្តិច ក៏ក្រាបបង្គំទូលថា " សូមទ្រង់ព្រះមេត្តាប្រោស ហ្វូងក្អែកដែលទំលើដើមឈើនោះ ជាហ្វូងក្អែកស្រុកក្រៅ ឯហ្វូងក្អែកដែលទំលើដំបូលមហាប្រាសាទនោះ ជាហ្វូងក្អែកនៅក្នុងក្រុងនេះ " ។ ព្រះរាជាឮដូច្នោះ ក៏ត្រាស់សួរទៅវិញថា " ចុះក្អែកស្រុកក្រៅវាមកយំកងតើវាយំថាដូចម្តេច ? ក្អែកក្នុងក្រុង  តើកញ្ជ្រៀវថា ដូចម្តេច ? " ។ អ្នកឧកញ៉ាក្រាបទូលថា " ក្អែកស្រុកក្រៅ មានក្តីក្តៅក្រហាយ ដោយអ្នកស្រុកក្រៅពុំបានធ្វើបុណ្យឱ្យទាន ដូចអំពីឆ្នាំមុនៗគឺឆ្នាំមុនៗ ប្រជារាស្ត្រសម្បូណ៌ស្រូវអង្ករ គេនាំគ្នាធ្វើបុណ្យនិមន្តលោកសង្ឃឆាន់ តាមភូមិលំនៅ ឯចំណីអាហារដែលសេសសល់នោះ គេបោះឱ្យទានក្អែក ឬសត្វឯទៀតៗផង បណ្តាសត្វទាំងឡាយមានក្អែកជាដើម សឹងបានបរិភោគចំណីដែលសល់នោះទូទៅ សេចក្តីសុខសប្បាយក៏មានគ្រប់តំបន់ ឥឡូវឆ្នាំនេះលោកឧកញ៉ាពលទេពជានាយក្សេត្រ ចាត់មេកងអាជ្ញាហ្លួងចេញទៅកត់ស្រូវ មិនត្រូវតាមប្រពៃណី គឺយកពន្ធរាស្ត្រលើសប្រមាណ រាស្ត្រគ្នាមានស្រូវតែត្រឹម ៤-៥ ថាំងក៏កត់គ្នាឱ្យជាប់ពន្ធដែរ ឧកញ៉ាពលទេពឱ្យកត់ដល់ទៅស្រូវពូជ ស្រូវដំណើប ស្រូវចំការប្រាំង យកជាពន្ធទាំងអស់ មួយទៀតស្រូវគ្នាមានតែត្រឹម ៥០-៦០ក៏ទារយកបង្កើនដាក់ថា ៩០-១០០រាស្ត្រគ្នាតវ៉ាក៏មិនបាន យកបុណ្យស័ក្តិ

សង្កត់បង្គ្របគ្នាទៅតាមអំពើចិត្តផ្សេងៗ ពួកប្រជារាស្ត្រកើតក្តីក្រលំបាកបានក្តីក្តៅក្រហាយ តែរាល់ៗគ្នា បានជាឆ្នាំនេះមិនមាននរណាអាចធ្វើបុណ្យឱ្យទាន់ដូចឆ្នាំមុនៗបាន ពួកក្អែកទាំងឡាយពុំបានទទួលទានបាយសម្ល ដែលសេសសល់អំពីការបុណ្យ ទាននោះឯង ទើបវានាំគ្នាចូលមកក្នុងក្រុង ដើម្បីថ្លែងសេចក្តីលំបាករបស់រាស្ត្រដល់ពួកក្អែកបណ្តាញាតិនៅក្នុងក្រុងឱ្យពួកក្អែកក្នុងក្រុង នាំសេចក្តីក្តៅក្រហាយឡើងក្រាបបង្គំទូល ព្រះករុណាជាម្ចាស់ផែ្ទក្រោមឱ្យទ្រង់ជ្រាប ការឧកញ៉ាពលទេពប្រព្រឹត្តខុស ព្រះរាជបញ្ញត្តិមានសភាពយ៉ាងនេះ សូមល្អងធូលីព្រះបាទស្តេចទ្រង់ជ្រាប " ។

ព្រះបរមរាជា បានទ្រង់ព្រះសណ្តាប់ពាក្យឧកញ៉ាយោមរាជដូច្នោះ ក៏ត្រូវព្រះទ័យទើបទ្រង់ខ្ញាល់នឹងឧកញ៉ាពលទេពថា កោងកាចឆបោករាស្ត្រ ធ្វើឱ្យប្រជារាស្ត្រក្តៅក្រហាយទាំងព្រះរាជអាណាខេត្ត ស្តេចទ្រង់ឱ្យដកងារឧកញ៉ាពលទេពចេញចាកមុខងារមន្ត្រី ប្រោសប្រទានឧកញ៉ាយោមរាជឡើងទីជាសម្តេចជហ្វាទឡ្ហ អគ្គមហាសេនាស្តីទីរាជការជាអធិបតីក្រសួងនានាតទៅ ។